ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាមនាមប្រជារាស្ត្រខ្មែរ

# សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ:៩៣៩/០១.១០.២០១២

សាលដីកា

លេខ:១៥៧ក្រIVអ/២៨.១១.២០១៣

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ: ០៦ក្រ ចុះថ្ងៃទី០៨-២-១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នា ថ្ងៃទី២៨.១១.២០១៣ ដែលមានសមាសភាព ដូចតទៅ៖

## សមាសភាពក្រុមប្រឹក្សា

លោក [redacted] ជាប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

## តំណាងមហាអយ្យការ

លោក [redacted]

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃរឿងព្រហ្មទណ្ឌ លេខ:៩៣៩ ចុះថ្ងៃទី០១.១០.២០១២ រវាង:

-ជនជាប់ចោទ ឈ្មោះ [redacted] ធារ៉ា ភេទប្រុស កើតឆ្នាំ១៩៨៦ ជាតិខ្មែរ មុខរបរធ្វើជាងភ្លើង កើតនៅភូមិម្កាក់ ឃុំម្កាក់ ស្រុកសិរីសោភ័ណ ខេត្តបាត់ដំបង ។ អាស័យដ្ឋានបច្ចុប្បន្ន [redacted] ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ទោសពីមុនគ្មាន ។

-ក្រៅឃុំ ។

-ជាប់ចោទពីបទៈ ហឹង្សាដោយចេតនា មានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅ ភូមិម្កាក់ សង្កាត់ម្កាក់ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១១ ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោស តាមមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] គឹមណេង ភេទស្រី កើតឆ្នាំ១៩៥៩ ជាតិខ្មែរ រកស៊ីធ្វើស្រែ កើតនៅ ភូមិម្កាក់ ឃុំម្កាក់ ស្រុកសិរីសោភ័ណ ខេត្តបាត់ដំបង ។ អាស័យដ្ឋានបច្ចុប្បន្ន [redacted] ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។ ឪពុកឈ្មោះ អៀន [redacted] (ស) ម្តាយឈ្មោះ [redacted](ស) ប្តីឈ្មោះ [redacted]មានកូន០២នាក់ ។

**៦រឿងហេតុមានដូចតទៅ**

-កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១១ វេលាម៉ោង៦ និង៣០នាទីល្ងាច ឈ្មោះ [redacted] ស៊ីណាល់ បានជិះម៉ូតូទៅលេងផ្ទះឈ្មោះ យុ នៅភូមិដូនឡី ។ ចំណែកនៅផ្ទះរបស់ឈ្មោះ [redacted] ហៃ ស្ថិតនៅក្នុងភូមិម្កាក់ សង្កាត់ម្កាក់ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ មានកម្មវិធីស៊ីផឹក មានគ្នា៦នាក់ចូលរួម គឺឈ្មោះ [redacted] ធារ៉ា, ឈ្មោះ ជាតិ, ឈ្មោះ [redacted] រី, ឈ្មោះ ធឿន, ឈ្មោះ រ៉ូ និងប្រពន្ធរបស់ឈ្មោះ រ៉ូ ។ ម៉ោង៨យប់ ឈ្មោះ [redacted] ស៊ីណាល់ បានជិះម៉ូតូតែម្នាក់ឯងត្រឡប់មកផ្ទះខ្លួនវិញ ។ ឈ្មោះ [redacted] ស៊ីណាល់ ជិះម៉ូតូដល់ចំណុចផ្លូវលំខាងជើងវត្តម្កាក់ បានបង្អង់ល្បឿនម៉ូតូនិយាយទូរស័ព្ទជាមួយម្តាយ ស្រាប់តែឈ្មោះ [redacted] ធារ៉ា ស្ទុះចេញពីកៀនរបងមកពីមុខម៉ូតូហើយវាយឈ្មោះ [redacted] ស៊ីណាល់ ត្រូវចំក្តោងច្រមុះបណ្តាលឲ្យធ្លាក់ពីលើម៉ូតូដួលផ្កាប់មុខ ។

បានឃើញសាលក្រមព្រហ្មទណ្ឌ លេខ៦៧ (ច) ចុះថ្ងៃទី២៧.កក្កដា.២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅៈ

I.ផ្តន្ទាទោសលើឈ្មោះ[redacted]ធារ៉ា ភេទប្រុស កើតឆ្នាំ១៩៨៦ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់២ឆ្នាំ (ពីរឆ្នាំ) តែទោសនេះត្រូវព្យួរទោសធម្មតា ក៏ប៉ុន្តែប្រសិនបើក្នុងរយៈពេល៥ឆ្នាំ បន្ទាប់ពីសាលក្រមនេះចូលជាស្ថាពរហើយ មានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀត ពីបទឧក្រិដ្ឋ ឬមជ្ឈិម ការព្យួរនេះត្រូវដកហូតចេញវិញដោយពេញច្បាប់ អនុលោមតាមមាត្រា១០៦, ១០៧, ១០៨, ១០៩ នៃក្រមព្រហ្មទណ្ឌ ។

ពីបទ ហឹង្សាដោយចេតនាមានស្ថានទម្ងន់ទោស ប្រព្រឹត្តនៅ ភូមិម្កាក់ សង្កាត់ម្កាក់ ក្រុងសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១១ ។ បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២១៨ នៃក្រមព្រហ្មទណ្ឌ ។

II.បង្គាប់ឲ្យឈ្មោះ [redacted] ធារ៉ា បង់ប្រាក់សំណងព្យាបាលរបួសស្នាមជនរងគ្រោះ និងសំណងជំងឺចិត្តសរុបចំនួន ៣,០០០,០០០រៀល(បីលានរៀល) ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] គឹមណោង ។ ក្នុងករណីរឹងរូសមិនព្រមបង់ប្រាក់ឲ្យអនុវត្តបង្ខំ ដល់រូបកាយតាមមាត្រា៥២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

III.សម្រេចរឹបអូសប្រាក់ចំនួន ១,៧០០,០០០រៀល (មួយលានប្រាំពីរសែនរៀល) ដែលជនជាប់ចោទបានបង់ដាក់ប្រាក់តំកល់ ដើម្បីទូទាត់ជាសំណងទៅដើមបណ្តឹងរដ្ឋប្បវេណី ។

IV.សាលក្រមនេះជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១២ និងប្រកាសជាសាធារណៈ នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១២ ចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី បើកសិទ្ធិឲ្យប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

-បានឃើញ សេចក្តីសុំប្តឹងតវ៉ាលេខ ៧១ ចុះថ្ងៃទី០៧.៨.២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ធារ៉ា ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ៦៧ "ច" ចុះថ្ងៃទី២៧.៨.២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចទី២ ។

-បានឃើញ សេចក្តីសុំប្តឹងតវ៉ាលេខ ៧២ ចុះថ្ងៃទី១០.៨.២០១២ របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] គឹមណោង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខៈ៦៧ "ច" ចុះថ្ងៃទី២៧.៨.២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

-បានឃើញរបាយការណ៍ របស់ចៅក្រមរបាយការណ៍សាលាឧទ្ធរណ៍ ចុះថ្ងៃទី១៣ ខែ១២ ឆ្នាំ២០១២ ។

-បានឃើញសេចក្តីសន្និដ្ឋាន របស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី២៥-១២-២០១២ ។

**<u>នាពេលសវនាការ</u>**

-ជនជាប់ចោទ ឈ្មោះ [redacted] ធារ៉ា (វត្តមាន)

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] គឹមណោង (វត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍ និងសង្ខេបរឿងជូនអង្គសវនាការ

-ជនជាប់ចោទ ឈ្មោះ [redacted] ធារ៉ា បានឆ្លើយថាៈ ខ្លួនមានមុខរបរជាងភ្លើង សព្វថ្ងៃនៅក្រៅឃុំ មិនធ្លាប់មានទោសពីមុនមកទេ ។ ខ្ញុំប្តឹងឧទ្ធរណ៍ត្រង់ចំណុចទី២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ លើសំណង៣លានរៀល ខ្ញុំមិនសុខចិត្តទេ ព្រោះច្រើនពេក ព្រោះខ្ញុំអត់បានវាយឈ្មោះ [redacted] ស៊ីណាល់ ទេ ។

សំណូមពរៈ សុំលោកតុលាការរកយុត្តិធម៌អោយខ្ញុំផង ។

-ដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ [redacted] គីមណេង បានឆ្លើយថាៈចំពោះការព្យាបាលកូនខ្ញុំអស់១,៧០០,០០០រៀល (មួយលានប្រាំពីរសែនរៀល) ខ្ញុំមានវិក័យប័ត្រដាក់ជូនតុលាការអស់ហើយ ខ្ញុំប្តឹងឧទ្ធរណ៍មិនសុខចិត្តព្រោះជនជាប់ចោទមិនសងប្រាក់៣,០០០,០០០រៀល(បីលានរៀល) មកខ្ញុំ ។

-សំណូមពរៈ សុំឲ្យតុលាការសម្រេច ឲ្យជនជាប់ចោទសងប្រាក់មកខ្ញុំចំនួន៣,០០០,០០០រៀល(បីលានរៀល) ។

-តំណាងមហាអយ្យការ ធ្វើសេចក្តីសន្និដ្ឋានៈ ក្រោយពីបានស្តាប់របាយការណ៍ក្រោយពីបានស្តាប់ការដេញដោល និងក្រោយពីបានពិនិត្យឯកសារក្នុងសំណុំរឿងមកឃើញថា ដោយអង្គហេតុពាក់ព័ន្ធតែលើសំណងរដ្ឋប្បវេណី ជនជាប់ចោទមិនប្តឹងឧទ្ធរណ៍លើទណ្ឌកម្មប្តឹងតែសំណង ។

-សុំក្រុមប្រឹក្សាពិនិត្យលើព្យសនៈកម្ម កើតឡើង និងពិនិត្យទៅលើសំណង ។

-ក្រោយពីបានអាន និងស្តាប់ចម្លើយជនជាប់ចោទ ។

-ក្រោយពីបានអានចម្លើយជនរងគ្រោះ ។

-ក្រោយពីបានអាន និងស្តាប់ចម្លើយដើមបណ្តឹង ។

-ក្រោយពីបានស្តាប់តំណាងមហាអយ្យការសន្និដ្ឋាន ។

-ក្រោយពីបានពិនិត្យឯកសារពាក់ព័ន្ធល្អិតល្អន់ ។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ ។

## សាលាឧទ្ធរណ៍

-យល់ឃើញថា ៖

១.បណ្តឹងឧទ្ធរណ៍លេខ៧១ ចុះថ្ងៃ៧.សីហា.២០១២ របស់ឈ្មោះ [redacted] ផារ៉ាជាជនជាប់ចោទ ត្រង់ចំណុចទី២ នៃសេចក្តីសម្រេច និងបណ្តឹងឧទ្ធរណ៍លេខៈ៧២ ចុះថ្ងៃ១០.សីហា.២០១២ របស់ឈ្មោះ [redacted] គីមណេង ជាដើមបណ្តឹងរដ្ឋប្បវេណី ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។ សាលាឧទ្ធរណ៍ទទួលជំនុំជំរះបាន ។

២.តាមវិញ្ញាបនប័ត្រពេទ្យគ្លីនិកវិសាលសុខខេត្តបន្ទាយមានជ័យ លេខ១០/០១១ ចុះថ្ងៃ៤.១០.២០១១ បញ្ជាក់ថា អ្នកជម្ងឺឈ្មោះ [redacted] ស៊ីណាល់ ចូលសំរាកព្យាបាលថ្ងៃ២.១០.២០១១ (ឯ.២) មានស្នាមរបួសដាច់សាច់នៅសៀតផ្កាស្តាំ និងហើមទំហំ៥×៥cm

របួសលើចិញ្ចើមឆ្វេង, ក្តោងច្រមុះ, លើថ្ពាល់ស្តាំ ទំហំ២×៦cm លើបបូរមាត់ និងដាច់អណ្តាតពាក់កណ្តាលមួយចំហៀង ខាងស្តាំ ។ របួសទាំងអស់នេះអាចសះជាក្នុងរយៈ១៥ទៅ២០ថ្ងៃក្រោមការព្យាបាលត្រឹមត្រូវ ។ ឃើញថាព្យសនកម្មដែលបង្កឡើងដោយជនជាប់ចោទ មានចំនួនច្រើន គប្បីតម្កល់សេចក្តីសម្រេចរបស់តុលាការ ទុកជាបានការ ។

៣.ដើមបណ្តឹងប្តឹងទាមទារសំណងបន្ថែមសរុប១០លានរៀល តែនៅពេលសវនាការសាលាដំបូង ឈ្មោះ [redacted] គឹមណោង អះអាងថា បានព្យាបាលកូនអស់១លាន៧សែនរៀល ។ គប្បីតម្កល់សេចក្តីសម្រេចរបស់សាលាដំបូងនៅដដែល ។

៤.សាលក្រមព្រហ្មទណ្ឌលេខ៦៧ (ច) ចុះថ្ងៃ២៧.៧.២០១២ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចទី២ មានលក្ខណៈត្រឹមត្រូវ គួរតម្កល់ទុកជាបានការ ។

**<u>ហេតុដូចនេះ វិនិច្ឆ័យសេចក្តី</u>**

១.ទទួលបណ្តឹងឧទ្ធរណ៍ លេខ៧១ ចុះថ្ងៃ៧.សីហា.២០១២ របស់ឈ្មោះ [redacted] ធាវ៉ា ជាជនជាប់ចោទ និងបណ្តឹងឧទ្ធរណ៍លេខ៧២ ចុះថ្ងៃ១០.សីហា.២០១២ របស់ឈ្មោះ [redacted] គឹមណោង ជាដើមបណ្តឹងរដ្ឋប្បវេណី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់គតិច្បាប់ ។

២.តម្កល់សាលក្រមព្រហ្មទណ្ឌលេខ៦៧(ច) ចុះថ្ងៃ២៧.កក្កដា.២០១២ ត្រង់ចំណុចទី២ នៃសេចក្តីសម្រេចរបស់សាលាដំបូងខេត្តបន្ទាយមានជ័យ ទុកជាបានការ ។

៣.សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទ និងដើមបណ្តឹង ។

បើកផ្លូវប្តឹងសាទុក្ខ តាមកំណត់ច្បាប់ ។

**<u>សេចក្តីនេះ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួល បន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ច គ្រប់ថ្នាក់ គ្រប់តំណែង និងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្ត សាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់</u> ។**

**ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

**ហត្ថលេខា [redacted] ហត្ថលេខា [redacted] , [redacted] ហត្ថលេខា [redacted]**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី05 ខែ......ឆ្នាំ២០១4

**បានឃើញ**

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

**ក្រឡាបញ្ជី**

[redacted]